លោកុប្បត្តិ១៩:៦-២០:១៨

**នោះឡុតចេញមកឯគេដល់មាត់ទ្វារ រួចបិទទ្វារទៅវិញ គាត់អង្វរថា បងប្អូនខ្ញុំអើយ សូមកុំធ្វើអាក្រក់ដូច្នេះឡើយ (លោកុ.១៩:៦-៧)។**

ពួកប្រុសៗនៅទីក្រុងសូដុំម បាននាំគ្នាមកឈរនៅមាត់ទ្វារផ្ទះឡុត ដើម្បីទាមទារសុំយកភ្ញៀវនោះទៅរួមរក្ស។ ប៉ុន្តែ លោកឡុតបានឆ្លើយតបទៅគេវិញថា "ខ្ញុំអង្វរដល់បងប្អូនរាល់គ្នា កុំអោយធ្វើអាក្រក់ដូច្នេះឡើយ"។ លោកឡុតឃើញអំពើដែលពួកប្រុសៗទាំងនោះ ប៉ងធ្វើអំពើអាក្រក់មកលើលោក ទោះបីលោកជាអ្នកស្រុកនោះ ជាយូរណាស់មកហើយក៏ដោយ។ ដំណើររឿងនេះ មិនមែនជារឿង ខ្វះសីលធម៌ថ្មីមួយទៀតសម្រាប់លោកទេ ប៉ុន្តែ រឿងនោះ ជារឿងអាក្រក់ប្រចាំត្រកូល ទីក្រុងសូដុំមទៅហើយ។

**មើល ខ្ញុំមានកូនស្រី២នាក់ វាមិនទាន់ដែលស្គាល់ប្រុសណាទេ ចាំខ្ញុំនាំវាចេញមក ប្រគល់ឱ្យអ្នករាល់គ្នាប្រព្រឹត្តនឹងវាតាមតែចិត្តចុះ សូមកុំឱ្យតែធ្វើអ្វីដល់មនុស្សទាំង២នោះឡើយ ពីព្រោះលោកបានចូលមកសំណាក់នៅផ្ទះខ្ញុំហើយ (លោកុ.១៩:៨)។**

នៅក្នុងសម័យដើម មានប្រពៃណីមួយយ៉ាងដូច្នេះថា បើបុគ្គលណាម្នាក់ទទួលមនុស្សដំទៃ មកធ្វើជាភ្ញៀវរបស់ផ្ទះខ្លួន បុគ្គលនោះត្រូវទទួលស្លាប់រស់ ជាមួយនឹងភ្ញៀវនោះតែម្តង។ ដោយសារប្រពៃណីនេះហើយ បានជាយើងឃើញលោកឡុតស្ម័គ្រចិត្តប្រគល់កូនស្រីទាំងពីររបស់លោក ដើម្បីការពារជីវិតរបស់ភ្ញៀវ ដែលលោកអញ្ជើញមកសំណាក់នៅផ្ទះលោកនោះ!

**តែគេកំហែងទៅថា ចូរចៀសចេញ ហើយមានខ្លះគេនិយាយថា អា១នេះបានចូលមកស្នាក់នៅទីនេះ ឥឡូវចង់តាំងខ្លួនធ្វើជាចៅក្រមវិញ អើបើដូច្នេះយើងនឹងធ្វើឯងឥឡូវ ឲ្យអាក្រក់ជាង២នាក់នោះទៅទៀតផង រួចគេក៏ប្របជ្រៀតលើឡុតជាខ្លាំង ព្រមទាំងរំលោភចូលទៅជិតចង់ទំលាយទ្វារ (លោកុ.១៩:៩)។**

"គេកំហែងទៅថា "...អាមួយនេះ បានចូលមកស្នាក់នៅទីនេះ ឥឡូវចង់តាំងខ្លួនធ្វើជាចៅក្រមវិញ..."។ បងប្អូនអើយ ត្រង់នេះយើងឃើញថា លោកឡុតមិនមែនគ្រាន់តែ ចូលទៅស្នាក់នៅទីក្រុងនោះធ្វើជាមនុស្សធម្មតាទេ ប៉ុន្តែ លោកជាអ្នកមានមុខមានមាត់ធំដុំ នៅទីក្រុងនោះផងដែរ។

**តែទេវតាលូកដៃទៅចាប់ឡុតទាញចូលមកក្នុងផ្ទះវិញ រួចបិទទ្វារជិត ក៏ធ្វើឱ្យមនុស្សទាំងអស់ដែលនៅត្រង់មាត់ទ្វារនោះ ខ្វាក់ភ្នែកទៅ ទាំងតូច ទាំងធំបានជាគេអស់ចិត្ត នឹងរកទ្វារទៀត (លោកុ.១៩:១០-១១)។**

បើកុំតែមានភ្ញៀវរបស់លោកឡុត ចេញទៅធ្វើអន្តរាគមន៍បែបនោះ លោកឡុតត្រូវគេធ្វើទុក្ខបុកម្នេញទៅហើយ ពីព្រោះមនុស្សនៅទីក្រុងសូដុំម មានចិត្តអាក្រក់ឃោរឃៅយ៉ាងខ្លាំងណាស់។

**រួចទេវតាសួរឡុតថា តើឯងមានអ្នកណាទៀតនៅទីនេះឬទេ ទោះបើកូនប្រសា ឬកូនប្រុសកូនស្រីឯងក្តី ចូរនាំពួកឯងទាំងអស់ចេញពីទីក្រុងនេះទៅ ដ្បិតយើងនឹងបំផ្លាញទីនេះ ពីព្រោះសំរែករបស់គេបានឮកាន់តែខ្លាំងឡើង នៅចំពោះព្រះយេហូវ៉ាហើយ នេះគឺព្រះយេហូវ៉ាទ្រង់បានចាត់ឱ្យយើងមកបំផ្លាញចេញ នោះឡុតក៏ចេញទៅប្រាប់ដល់កូនប្រសា ដែលបានយកកូនស្រីគាត់ថា ចូរក្រោកឡើងចេញពីទីនេះទៅ ពីព្រោះព្រះយេហូវ៉ាំរៀបនឹងបំផ្លាញទីក្រុងចោល តែពួកកូនប្រសាគាត់ស្មានថា គាត់និយាយលេងទេ (លោកុ.១៩:១២-១៤)។**

ករណីខាងលើយើងឃើញថា ស្ថានភាពជីវិតរបស់លោកឡុត ធ្លាក់ដល់បាតដាល។ លោកបានតាំងទីលំនៅ នៅក្នុងទីក្រុងសូដុំមនេះ ជាយូរយារណាស់មកហើយ។ លោកមាន ការអត់ឱនដល់អំពើអាក្រក់ ទាំងអម្បាលមាណ នៅក្នុងទីក្រុងនោះ ថ្វីដ្បិតលោកយល់ថា អំពើទាំងនោះពិតជាអាក្រក់មែន។ លោកមានកូនប្រុសកូនស្រី ដែលធំដឹងក្តីនៅក្នុងទីក្រុងនោះ ហើយពួកកូនលោកខ្លះ បានរៀបការជាមួយនឹងមនុស្សអាក្រក់ទាំងនោះដែរ។ ក្នុងខណៈដែលព្រះជាម្ចាស់ បង្គាប់អោយលោកឡុត ចេញពីទីក្រុងនោះ គាត់បានទៅប្រាប់ កូនប្រសាគាត់យ៉ាងដូច្នេះថា "ចូរនាំគ្នាចេញពីទីនេះទៅពីព្រោះព្រះយេហូវ៉ា រៀបនឹងបំផ្លាញទីក្រុងនេះចោលហើយ"។ ពួកកូនប្រសាររបស់លោកសើចចំអកអោយលោក ព្រមទាំងសម្តែងការមើលងាយ មើលថោកដល់លោកទៀតផង។ ខ្ញុំគិតថា ប្រហែលជាពួកកូនប្រសាទាំងនោះ ឃើញលោកឡុតទិញដីមួយកន្លែងទៀត កាលពីសប្តាហ៍មុននេះសោះ ហេតុអ្វីបានជាគាត់ ហ៊ានចាកចោលដី ដែលគាត់ទើបនឹងទិញនោះកើត។ លោកឡុតរស់នៅទីនោះ ជាយូរមកហើយ ឯអត្តចរិករបស់លោក មិនមានអ្វីធ្វើអោយគេចាប់ភ្លឹក ថាគាត់ជាមនុស្សខុសប្លែកពីគេទេ។ ដូច្នេះហើយបានជាពួកកូនប្រសាររបស់លោក មិនយកពាក្យរបស់លោកថា ជាការពិត ពោលគឺគេជឿថា "គាត់និយាយលេងទេ"។ លោកឡុតបានស្ម័គ្រចិត្ត មកនៅទីក្រុងនេះ ខុសព្រះហឫទ័យបំណងរបស់ព្រះ ហើយគាត់ ក៏មិនដែលធ្វើបន្ទាល់ ដល់អ្នកដទៃអំពីព្រះជាម្ចាស់ដែរ។ បើតាមយើងវិនិច្ឆ័យនៅក្នុងអត្ថបទនេះ យើងឃើញថា លោកឡុត មិនដែលបាននាំអ្នកណាសូម្បីម្នាក់សោះ មកថ្វាយដល់ព្រះជាម្ចាស់ទេ។ សព្វថ្ងៃគោលការណ៍របៀបនេះ នៅមាន

ដដែល ពោលគឺពេលដែលលោកអ្នកបងប្អូន បានធ្លាក់ទាបដល់កំរិតស្មើនឹងពួកមនុស្ស មានបាបទាំងនេះហើយ លោកអ្នកមិនអាចទាញ នាំគេអោយមក ស្គាល់ព្រះជាម្ចាស់ នៃយើងបានឡើយ។ ខ្ញុំគិតថា ឆាកដែលលោកឡុត កំពុងតែសម្តែង គឺជាឆាកដែលគ្រីស្ទបរិស័ទមានប្រភេទដូចលោកឡុត កំពុងសម្តែងសព្វថ្ងៃនេះដែរ។

និយាយតាមត្រង់ចុះ ខ្ញុំពិតជាយល់ស្រប ជាមួយនឹងលោកអ័ប្រាហាំ ដែលគិតថា លោកឡុតប្រហែលជាមិនទាន់រួចពីបាបទេមើលទៅ ប៉ុន្តែ សូមលោកអ្នកវិនិច្ឆ័យលោកឡុត ពីព្រះបន្ទូលដែលទ្រង់មានបន្ទូលក្នុងគម្ពីរពេត្រុសយ៉ាងដូច្នោះថា" ហើយបើទ្រង់បានបញ្ឆេះក្រុងសូដុំម និងក្រុងកូម៉ូរ៉ាអោយទៅជាផេះ ទាំងកាត់ទោសអោយត្រូវហិនវិនាសសាបសូន្យទៅ ទុកជាគំរូដល់ពួកមនុស្សតទៅមុខ ដែលគិតរស់នៅដោយសេចក្តីទមិឡល្មើស តែបានប្រោសលោកឡុត ជាអ្នកសុចរិតអោយរួចវិញ ដែលលោកមានចិត្តព្រួយលំបាក ដោយព្រោះកិរិយាខូចអាក្រក់របស់មនុស្សទទឹងច្បាប់ទាំងនោះ ដ្បិតអ្នកសុចរិតនោះ ដែលនៅជាមួយនឹងគេ ក៏កើតទុក្ខក្នុងចិត្តសុចរិតរបស់លោករាល់តែថ្ងៃ ដោយបានឮ ហើយឃើញការទទឹងច្បាប់ ដែលគេប្រព្រឹត្តធ្វើ" (២ពេត្រុស២:៦-៨)។ ខ្ញុំសូមជំរាប លោកអ្នកបងប្អូនយ៉ាងដូច្នេះថា លោកឡុតមិនដែលឃើញមានក្តីសប្បាយសោះ តាំងពីគាត់ទៅរស់នៅក្នុងទីក្រុងសូដុំមនេះ។ ពេលនេះគាត់ត្រូវចាកចេញពីទីក្រុងទៀត ហើយម្តងនេះគ្មាននរណាព្រមចេញទៅជាមួយគាត់ទេ លើកលែងតែភរិយារបស់លោក និងកូនក្រមុំពីរនាក់ដែលនៅលីវនៅឡើយ។

**លុះពេលភ្លឺឡើង នោះទេវតាបង្ខំឡុតថា ចូរក្រោកឡើងយកប្រពន្ធហើយនិងកូនស្រីឯងទាំង២នាក់ ដែលនៅឯណេះទៅ ក្រែងឯងត្រូវវិនាសក្នុងអំពើទុច្ចរិតរបស់ទីក្រុងនេះដែរ តែគាត់នៅបង្អែបង្អង់ នោះទេវតាក៏ចាប់ដៃគាត់និងដៃប្រពន្ធហើយនិងកូនស្រីគាត់ទាំង២នាំចេញទៅលែងឯក្រៅទីក្រុង ដ្បិតព្រះយេហូវ៉ាទ្រង់មេត្តាប្រណីដល់គាត់ (លោកុ.១៩:១៥-១៦)។**

លោកឡុតពិតជាមនុស្ស ដែលជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់មែន ទោះបីជីវិតគាត់រស់នៅប្រៀបឧបមាដូចភ្លើងឆេះផ្ទះក៏ដោយ។ បើប្រសិនណាជាខ្ញុំ គ្រាន់តែអានព្រះគម្ពីរលោកុប្បត្តិ ត្រង់ដែលយើងទើបនឹងអានអម្បាញមិញនេះ ខ្ញុំជឿប្រាកដថា លោកឡុត ពិតជាមិនបានទទួលសេចក្ដីសង្គ្រោះទេ។ ប៉ុន្តែ ព្រះគម្ពីរពេត្រុសបានហៅ លោកថាជាមនុស្សសុចរិត ហើយយើងក៏ទទួលយល់ស្របជាមួយ នឹងព្រះគម្ពីរនេះ យ៉ាងដូច្នេះដែរ។ លោកឡុតបានទទួលឈ្មោះថា ជាមនុស្សសុចរិត ពីព្រោះលោកឡុតបានជឿដល់ព្រះជាម្ចាស់។ ព្រះជាម្ចាស់សម្ដែងព្រះគុណរបស់ទ្រង់ ចំពោះលោកឡុតបាន ជាលោកជឿដល់ព្រះអង្គបន្តទៅទៀត រហូតគាត់ព្រមចាកចេញពីទីក្រុងជាលំនៅរបស់លោក។

**កាលបាននាំចេញផុតទៅក្រៅហើយនោះទេវតាប្រាប់ថា ចូររត់ទៅឱ្យបានរួចជីវិតចុះ កុំអោយមើលមកក្រោយឡើយ ក៏កុំ**

**ឱ្យឈប់នៅស្រុកវាលឯណាមួយផង ចូររត់ទៅឯភ្នំវិញ ក្រែង ឯងត្រូវវិនាសដែរ តែឡុតប្រកែកថា ទេលោកម្ចាស់អើយ មើល ឥឡូវនេះ លោកបានផ្តល់ព្រះគុណមកខ្ញុំជាអ្នកបម្រើលោក ហើយ បានចំរើនសេចក្តីមេត្តាករុណារបស់លោក ឱ្យខ្ញុំឃើញដោយការ ពារជីវិតខ្ញុំ តែខ្ញុំរត់ទៅឯភ្នំមិនបានទេ ក្រែងសេចក្តីអាក្រក់តាម ខ្ញុំទាន់ ហើយខ្ញុំត្រូវស្លាប់វិញ (លោកុ.១៩:១៧-១៩)។**

តាមការដោះសារខាងលើ លោកឡុត មិនមានចិត្តចង់ចេញពីទីក្រុងនោះប៉ុន្មាន ទេ ប៉ុន្តែ ដោយលោកជឿលើពាក្យរបស់ទេវតា បានជាលោកព្រមចាកចេញពីទីក្រុង នោះ។ ប៉ុន្តែ លោកមិនអាចធ្វើដំណើរទៅដល់ភ្នំ ដែលព្រះជាម្ចាស់ចង់អោយគាត់ទៅ ជ្រកកោននោះទេ។

**មើលន៍ មានទីក្រុង១នុ៎ះស្ថិតនៅជិតបង្កើយ ហើយក៏តូចផង ឬមិនតូចទេ នោះលួមនឹងរត់ទៅឱ្យរួចបាន សូមឱ្យខ្ញុំរត់ទៅឯ ណោះវិញ នោះខ្ញុំនឹងបានរួចជីវិតហើយ (លោកុ.១៩:២០)។**

លោកឡុតបានសុំទៅស្នាក់នៅ ក្នុងទីក្រុងតូចមួយហៅថា សូអា។ លោកអ្នក ឃើញទេត្រង់នេះថា លោកឡុតបានចេញពីទីក្រុងសូដុំម ប៉ុន្តែ គាត់មិនបានចេញ

ដោយសុឆន្ទៈជ្រះថ្លានោះសោះឡើយ។ នៅក្នុងពេលនេះ ខ្ញុំជឿថា លោកកំពុងទូលទុក្ខយ៉ាងខ្លាំង។

## ការបំផ្លាញទីក្រុងទាំងពីរមួនទាំងទាល់ទំនាប

ព្រះជាម្ចាស់បានរំលាយទីក្រុងទាំងពីរ គឺសូដុំមនិងកូម៉ូរ៉ាចោលទាំងស្រុងតែម្ដង។ ព្រះគម្ពីរបានសម្ដែង អោយយើងឃើញសេចក្ដីពីរ យ៉ាងទៀត ទីមួយទាក់ទងជាមួយនឹងភរិយារបស់លោកឡុត ទីពីរទាក់ទងជាមួយ នឹងកូនស្រីក្រមុំរបស់លោកទាំងពីរ។ សេចក្ដីដែលទាក់ទង នឹងភរិយារបស់លោក គឺមានហេតុការណ៍កើតឡើង ដូចខាងក្រោមនេះ។

**ឯប្រពន្ធឡុតក៏ងាកបែរមើលទៅក្រោយវិញ នោះស្រាប់តែទៅជាបង្គោលអំបិលទៅ (លោកុ.១៩:២៦)។**

ខ្ញុំយល់ថា មានមនុស្សភាន់ច្រឡំខគម្ពីរខាងលើនេះច្រើនណាស់។ ហេតុអ្វីបានជាប្រពន្ធលោកឡុត បែរមើលមកក្រោយ? ខ្ញុំយល់ថា មានមូលហេតុពីរយ៉ាង ដែលធ្វើអោយគាត់ងាកបែរក្រោយ។ ទីមួយគាត់មើលមកក្រោយ ពីព្រោះគាត់មិនចង់ចាកចេញពីទីក្រុងសូដុំមទាល់តែសោះ។ គាត់ស្រឡាញ់ទីក្រុងសូដុំមនេះណាស់។ គាត់ស្រឡាញ់

លោកឡុតដែរ ប៉ុន្តែ គាត់ស្តាយជីឡូត៍ដែលទើបនឹងទិញ ប៉ុន្មានថ្ងៃមុននេះជាជាង។ គាត់មិនចង់ចាកចេញពីជីឡូត៍នោះទេ។ មិនតែប៉ុណ្ណោះ គាត់ជាសមាជិករបស់ក្រុមផ្សេងៗ ដែលមាននៅក្នុងទីក្រុងនោះ។ គាត់ប្រហែលជាសមាជិក របស់ភាគហ៊ុនណាមួយ ឬជាសមាជិករបស់សមាគមណាមួយ អាចជាសមាជិករបស់ក្រុមស្ត្រី ឬមួយក៏ជាសមាជិក របស់ក្រុមកាន់សាសនាណាមួយផងក៏មិនដឹង។ តាមមើលទៅ គាត់ជាសមាជិករបស់ក្រុមទាំងអស់ ដែលមាននៅក្នុងទីក្រុងទាំងមូលផង។ ចិត្តរបស់គាត់ មិនដាច់អាល័យពីទីក្រុងសំដុំមឡើយ។ ពេលដែលគាត់ដើរចេញពីទីក្រុងសូដុំម មានកូនប្រុសកូនស្រីគាត់ដែលរៀបការរួចទៅហើយ ស្នាក់នៅទីនោះ ធ្វើអោយចិត្តគាត់ក៏នៅ ទីនោះជាមួយពួកកូនគាត់ដែរ។ កិរិយាបែរមើលក្រោយរបស់ភរិយាលោកឡុតនេះ បន្សល់ទុកនូវមេរៀន អោយយើងរៀនសូត្រសព្វថ្ងៃនេះ។ ខ្ញុំធ្លាប់ឮគ្រីស្ទបរិស័ទភាគ ច្រើននិយាយថាចង់អោយតែព្រះជាម្ចាស់យាងត្រឡប់មកវិញឆាប់ៗទេ ប៉ុន្តែ ទោះបីគេ មានចិត្តយ៉ាងដូច្នោះមែន គេមិនខ្វល់ពីរៀបចំជីវិតគេ បែបជាជីវិត ដែលត្រូវទៅនៅជា មួយព្រះអង្គនោះឡើយ។ នៅព្រឹកថ្ងៃអាទិត្យ គេរៀបចំទៅព្រះវិហារ តែពាក់កណ្តាលខ្លួនប៉ុណ្ណោះ។ យប់ថ្ងៃអាទិត្យដែល គេត្រូវមកអធិស្ឋាន មកថ្វាយបង្គំព្រះអង្គ គេមិនចង់ចាកចោលផ្ទះរបស់គេទេ ពីព្រោះគេចូលចិត្តរឿងភាគ ក្នុងទូរទស្សន៍ជាជាង។ ប៉ុន្តែពេលដែលព្រះជាម្ចាស់ទ្រង់យាងមក មិត្តសម្លាញ់អើយ លោកអ្នកត្រូវចាកចោលទូរទស្សន៍ ត្រូវចាកចោលផ្ទះសម្បែង ដែលជាទីមនោរម្យរបស់លោកអ្នក ថែមទាំងត្រូវចាកចោលអ្វីៗទាំងអស់ ដែលលោកអ្នកមាននៅលើលោកនេះផងដែរ។ ខ្ញុំសូមសួរដល់លោកអ្នកថា

ពេលដែលលោកអ្នក ចាកចេញពីលោកនេះ ទៅនៅជាមួយព្រះអង្គ តើលោកអ្នកពិបាកចិត្តណាស់ឬមួយយ៉ាងណា?

ខ្ញុំធ្លាប់សួរខ្លួនឯង នូវសំណួរនេះដែរ។ បើនិយាយតាមត្រង់ ខ្ញុំមិនសូវជាមានចិត្តចង់ចាកចោលផ្ទះសម្បែងខ្ញុំប៉ុន្មានទេ។ ខ្ញុំចង់នៅផ្ទះខ្ញុំ ចង់នៅជិតមិត្តភក្តិសាច់ញាតិជិតខាង ដែលខ្ញុំស្រឡាញ់រាប់អាន។ ម្យ៉ាងទៀត ខ្ញុំមានកម្មវិធីបង្ហាត់បង្រៀនតាមវិទ្យុបែបនេះ ខ្ញុំនៅមានចិត្តចង់ធ្វើតទៅទៀត។ និយាយរួម ខ្ញុំសង្ឃឹមថា ព្រះជាម្ចាស់ទុកអោយខ្ញុំ នៅលើលោកនេះបានវែងបន្តិចទៅទៀត។ តែទោះបីចិត្តរបស់ខ្ញុំ នៅទីមទាមយ៉ាងនេះក៏ដោយ ខ្ញុំរៀបចំចិត្តរួចស្រេចបាច់ហើយថា ពេលដែលព្រះអម្ចាស់ហៅខ្ញុំទៅនៅជាមួយទ្រង់ ខ្ញុំមិនមានការឈឺចាប់អ្វី នឹងលះចោលរបស់ទ្រព្យនៅលោកនេះទេ។ ខ្ញុំចង់ទៅជាមួយព្រះអង្គឆាប់ៗតែម្តង។ ខ្ញុំស្រឡាញ់ផ្ទះរបស់ខ្ញុំ នៅលោកីយ៍នេះ ប៉ុន្តែខ្ញុំស្រឡាញ់ផ្ទះរបស់ខ្ញុំ នៅស្ថានសួគ៌ជាជាង។ ខ្ញុំព្រមទៅជាមួយព្រះអង្គ មិនស្តាយស្រណោះ និងរបស់ទ្រព្យដែលមាននៅសល់ ពីខាងក្រោយខ្ញុំនោះទេ។ ចុះចំណែកលោកអ្នកវិញ តើមានអារម្មណ៍បែបណាដែរសព្វថ្ងៃនេះ ស្តីពីការទៅនៅជាមួយព្រះអង្គ? ភរិយារបស់លោកឡុត បែរមើលក្រោយ ហើយគាត់បានក្លាយទៅជាបង្គោល អំបិលទៅ។ ចុះលោកអ្នកវិញចង់បែរមើលទៅក្រោយដូចគាត់ ហើយក្លាយទៅជាបង្គោលអំបិលដូចគាត់ដែរឬទេ?

ចំណែកឯមូលហេតុទីពីរវិញ គឺគាត់មិនជឿដល់ព្រះបន្ទូល ដែលប្រកាសប្រាប់គាត់តែម្តង។ ព្រះជាម្ចាស់មានបន្ទូលទៅកាន់គាត់ថា ត្រូវចេញពីទីក្រុងនោះ កុំអោយ

មើលក្រោយអោយសោះ។ លោកឡុតមិនបានមើលក្រោយទេ ពីព្រោះគាត់ជឿលើព្រះបន្ទូលហាមប្រាម។ ប៉ុន្តែ ភរិយារបស់លោកឡុតវិញ មិនបានជឿដល់ព្រះអង្គសោះតែម្តង។ គាត់បែរមើលក្រោយ ហើយគាត់បានក្លាយត្រឡប់ទៅជាបង្គោលអំបិល។

ខ្ញុំមិនចង់ពន្យល់វែងឆ្ងាយ អំពីដំណើររឿង កូនស្រីទាំងពីររបស់គាត់ដែលបាននិយាយក្នុងខ៣១-៣៨នេះទេ។ រឿងនោះ ជារឿងអាក្រក់ជួរជាតិស្រាប់ទៅហើយ។ លោកឡុតមិនមានជីវិតល្អបរិបូរ ពេលដែលលោករស់នៅទីក្រុងសូដុំម។ លោកបាត់អ្វីទាំងអស់ ពេលដែលលោកនៅក្នុងទីក្រុងនោះ សល់តែព្រលឹងមួយគត់។ ជីវិតលោកឡុតជារូបភាព ឆ្លុះបញ្ចាំងដល់ជីវិតរបស់មនុស្សសព្វថ្ងៃនេះ ដែលមិនព្រមយកអំពើបាប ដែលជាប់នៅក្នុងជីវិតរបស់ខ្លួន មកត្រិះរិះពិចារណាទេ។ គ្រីស្ទបរិស័ទច្រើនណាស់ ដែលបានរួចពីបាបដែរ ប៉ុន្តែ" ដូចជាដើរកាត់ភ្លើង" ។ អ្នកទាំងនោះ ទូលពងមាន់ឆៅមួយកញ្ជើរដើរឆ្ពោះទៅស្ថានសួគ៌ ប៉ុន្តែ ប្រឡែងជាមួយអំពើបាបរបស់គេដូច្នេះហើយព្រះជាម្ចាស់នឹងជំនុំជំរះគេជាពិត។ ករណីលោកឡុត ដែលមានសម្តែងនៅក្នុងព្រះគម្ពីរនេះ ជាឧទាហរណ៍ស្រាប់ហើយ។

ឥឡូវនេះ សុំយើងបែរមកពិនិត្យមើលដំណើររបស់លោកអ័ប្រាហាំវិញម្តង។ តើលោកអ័ប្រាហាំមានគំនិតបែបណានៅក្នុងរឿងដែល ឡុតកំពុងឆ្លងកាត់នេះ?

**ឯអ័ប្រាហាំគាត់ក្រោកពីព្រលឹមឡើង នៅឯកន្លែងដែលបានឈរ**
**នៅចំពោះព្រះយេហូវ៉ា គាត់មើលទៅឯក្រុងសូដុំម ក្រុងកូម៉ូរ៉ា**

**និងស្រុកវាលទាំងអស់ ឃើញមានសុទ្ធតែផ្សែងហុយឡើងពីដីមក ដូចជាផ្សែងនៃគុកភ្លើង (លោកុ.១៩:២៧-២៨)។**

នៅពេលដែលលោកអ័ប្រាហាំ ក្រឡេកមើលទៅទីក្រុងសូដុំម ចិត្តរបស់លោក មានការក្តុកក្តួលណាស់។ ខ្ញុំមិនដឹងថា លោកបានជ្រាបហើយឬនៅថា ក្មួយលោកឈ្មោះ ឡុតនោះ បានរួចផុតពីគ្រោះអន្តរាយហើយ។ គាត់ប្រហែលជាដឹងរឿងនេះ ក្រោយមក ទៀតទេ។ ប៉ុន្តែ ខ្ញុំដឹងពិតប្រាកដថា ពេលដែលលោកមើលទៅទីក្រុងនោះ លោកមានចិត្ត ព្រួយបារម្ភ ព្រោះតែក្មួយរបស់លោកប៉ុណ្ណោះ។ ខ្ញុំជឿជាក់ថា លោកអ័ប្រាហាំមិនបាន ដាក់ទុនលុយកាក់រកស៊ីនៅទីក្រុងនោះទេ។ ពេលដែលទីក្រុងនេះ ទទួលការជំនុំជំរះ លោកមិនមានការអ្វីរំខានដល់ចិត្តលោកឡើយ ពីព្រោះលោកមិនស្រឡាញ់កិច្ចការ ដែល គេធ្វើនៅទីក្រុងនោះ ព្រមទាំងមិនស្រឡាញ់ដល់អ្វីៗទាំងអស់ដែលនៅលើលោកនេះ ផង។ សូមលោកអ្នកបងប្អូន នឹកចាំពីព្រះបន្ទូល ដែលសម្តែងថា "កុំអោយស្រឡាញ់ លោកីយ៍ ឬរបស់អ្វីដែលនៅក្នុងលោកីយ៍នេះអោយសោះ..." (១យ៉ូហាន២:១៥)។

ឥឡូវនេះ សុំលោកអ្នកសម្លឹងមើលទីក្រុងសូដុំម តាមក្រសែភ្នែក របស់មនុស្សពររូប។ ទីមួយ សូមលោកអ្នកសម្លឹងមើល តាមក្រសែភ្នែករបស់លោកឡុត។ លោកឡុតវិនិច្ឆ័យ តាមភាពឆើតឆាយរបស់ទីក្រុងនេះ។ ភរិយាលោកឡុតចាប់ចិត្ត ស្នេហាទីក្រុងនេះ ខ្លាំងក្រៃលែង។ ទីពីរ លោកអ្នកសម្លឹងមើលទីក្រុងសូដុំម តាមក្រសែ ភ្នែករបស់លោកអ័ប្រាហាំ។ លោកអ័ប្រាហាំ មិនមានខាតបង់អ្វីសោះ ពេលដែលទីក្រុង

នោះត្រូវហិនវិនាស។ ទីបី សូមលោកអ្នកបងប្អូន សម្លឹងមើលទីក្រុងនេះ តាមក្រសែព្រះនេត្ររបស់ព្រះជាម្ចាស់។ ព្រះអង្គទតមើលឃើញ អំពើបាបនៅក្នុងទីក្រុង នេះមានភាពទុំរលួយហើយស្អុយ ល្អមជ្រុះទៀតផង។ សព្វថ្ងៃនេះ ក្រុមជំនុំមិនបានមើលឃើញអំពើបាប ដែលស្រដៀងនឹងលេងកូនជីង កំពុងបង្កប់នៅក្នុងក្រុមជំនុំ ដូចជាព្រះអម្ចាស់ទ្រង់បានទតឃើញនោះឡើយ។ អ្នកលេងកូនជីង និងអ្នកប្រព្រឹត្តបាប ស្មើនឹងលេងកូនជីងច្រើនណាស់ ដែលបង្កប់ខ្លួននៅក្នុងក្រុមជំនុំរបស់ព្រះអង្គ។ អំពើបាបលាក់កំបាំងទាំងនោះ ទ្រង់ឃើញថាទុំល្អមជ្រុះផងដែរ។ ខ្ញុំនិយាយនេះ មិនមែននិយាយអោយតែឮ ប៉ុន្តែខ្ញុំនិយាយដោយឃើញអំពើបាបទាំងនោះ មានប្រព្រឹត្តពិតប្រាកដមែននៅក្នុងក្រុមជំនុំ ឯអំពើបាបទាំងនោះ ពួកយើងរាល់គ្នា កំពុងតែប្រព្រឹត្តផងដែរ។

ឆ្លៀតឱកាសនេះ ខ្ញុំសុំប្រកាសជំហរ របស់គ្រីស្ទបរិស័ទ ចំពោះមនុស្សដែលប្រព្រឹត្តបាបលេងកូនជីង។ តើយើងហៅកិរិយាប្រព្រឹត្តនោះថាជាអ្វី? សូម្បីលោកឡុតដែលរស់នៅក្នុងទីក្រុងសូដុំម លោកបានហៅកិរិយាលេងកូនជីងនេះ ថាជាអំពើអាក្រក់ជួរជាតិណាស់។ ព្រះជាម្ចាស់ជំនុំជំរះ កិរិយាប្រព្រឹត្តបែបនេះពិតប្រាកដ។ កូនរបស់ព្រះជាម្ចាស់ មិនត្រូវមានគំនិតសម្របសម្រួលជាមួយ នឹងកិរិយាបែបនេះជាដាច់ខាត។ កិរិយានេះជាអំពើបាប។ មនុស្សនៅក្នុងលោក លើកតំកើងមនុស្សខ្ទើយ ថាជាមនុស្សនេះមានជម្ងឺ។ ឯមនុស្សប្រមឹក ក៏មនុស្សនៅក្នុងលោកនេះ និយាយថា មនុស្សមានជម្ងឺដែរ។ មែនហើយ ទាំងអ្នកខ្ទើយ ទាំងអ្នកប្រមឹក សុទ្ធតែជាអ្នកមានជម្ងឺមែន។ ប៉ុន្តែហេតុអ្វីបានជាគាត់យកដៃទៅចាប់កែវស្រាផឹកមួយស្រឹដំបូង រួចហើយថែមមួយលីត្រ

រួចហើយថែមមួយដបទៀត រហូតដល់ធ្លាក់ខ្លួនឈឺ? លោកអ្នកបងប្អូនអើយ អំពើបាបបាននាំមុខគាត់! អ្នកលេងកូនជីង ជាអ្នកប្រព្រឹត្តអំពើបាបពេញទី។ ព្រះគម្ពីររ៉ូម បានសម្តែងពីរឿងនេះថា ជាអំពើបាប ហើយព្រះជាម្ចាស់ ប្រគល់មនុស្ស ដែលចង់ប្រព្រឹត្តអំពើបាបបែបនេះ អោយត្រេកត្រអាល នឹងរស់នៅក្នុង អំពើបាបរបស់ខ្លួន (សូមអានខគម្ពីររ៉ូម១:១៨-៣២)។ ព្រះគម្ពីរលោកុប្បត្តិជំពូក១៩នេះ សម្តែងពីរូបភាពរបស់មនុស្សយើង ដែលកំពុងរស់នៅសព្វថ្ងៃនេះ ថាជាមនុស្សដែលដាច់ឆ្ងាយពីព្រះអង្គ ធ្វើតាមតែអំពើដែលចិត្តខ្លួននឹកឃើញថាល្អ។

# ជំពូក ២០

*ផ្ទចេនា លោកអ័ប្រាហាំនិយាយមិនពិតពីដំណើរនាងសារ៉ា*

ជំពូក២០នេះ គឺជាជំពូកដែលលោកអ្នកបងប្អូនគិតថា គួរកុំអោយមាននៅក្នុងព្រះគម្ពីរធ្វើអ្វី ពីព្រោះយើងឃើញលោកអ័ប្រាហាំ ធ្វើអំពើបាបច្រំដែលម្តងទៀតហើយ។ ពេលលោកចុះទៅនៅស្រុកអេស៊ីព្ទ នៅចំពោះស្តេចផារ៉ោន លោកបាននិយាយមិនពិតថា"នាងសារ៉ាយជាប្អូនរបស់ទូលបង្គំ"។ ដំណើររឿងនោះ មានលក្ខណៈអាក្រក់ស្តាប់ណាស់។ ប៉ុន្តែ ទោះបីយ៉ាងនោះក៏ដោយជំពូក២០នេះ មានសារៈសំខាន់ណាស់។ លោកអ័ប្រាហាំ និងសារ៉ាត្រូវតែជំរះអំពើបាបរបស់ខ្លួន មុននឹងអាចទទួលយកកូនប្រុសមួយឈ្មោះអ៊ីសាក មកធ្វើជាកូនរបស់ខ្លួនផ្ទាល់។ ខ្ញុំសូមនិយាយទៅកាន់លោកអ្នកបងប្អូននៅថ្ងៃនេះដែរថា ល្គឹកណាបងប្អូនមិនបានជំរះអំពើបាប នៅក្នុងជីវិតរបស់លោកអ្នកផ្ទាល់ទេ ល្គឹកនោះមិនមានព្រះពរណាធ្លាក់មកដល់ជីវិតលោកអ្នករាល់ឡើយ។

## លោកអ័ប្រាហាំនិយាយមិនពិតពីដំណើរនាងសារ៉ា

នៅក្នុងជំពូក២០នេះ ខ្ញុំគ្រាន់តែចង់ពន្យល់ចំណុចធំៗខ្លះៗតែប៉ុណ្ណោះ។

**ឯអ័ប្រាហាំគាត់ចេញពីទីនោះធ្វើដំណើរទៅឯស្រុកត្បូង គាត់តាំងទីលំនៅត្រង់កេរ៉ា នាកណ្តាលកាដេសនិងសើរ អ័ប្រាហាំក៏និយាយពីសារ៉ាប្រពន្ធគាត់ថាជាប្អូនវិញ រួចអ័ប៊ីម្មាឡិចជាស្តេចកេរ៉ាទ្រង់ចាត់គេអោយទៅនាំយកសារ៉ាមក (លោកុ.២០:១-២)។**

ខគម្ពីរខាងលើនេះ បញ្ជាក់អោយឃើញសេចក្តីមួយដែលយើងត្រូវកត់សម្គាល់។ តើលោកអ្នកបងប្អូនជឿថា នាងសារ៉ាមានរូបសម្ផស្សឆើតឆាយមែនដែរឬទេ? មកដល់ពេលនេះ នាងសារ៉ាមានអាយុ៩៩ឆ្នាំហើយ ប៉ុន្តែនាងនៅតែមានរូបសម្រស់ឆើតឆាយដដែល។ សព្វថ្ងៃនេះ ស្ត្រីអាយុ៩៩ឆ្នាំមិនមានរូបសម្ផស្សឆើតឆាយដូចជានាងសារ៉ាទេ។ លោកអ័ប្រាហាំធ្វើដំណើរទៅស្រុកត្បូង ដើម្បីតាំងទីលំនៅនៅទីនោះ។ លោកបានធ្វើដំណើរ រហូតទៅដល់កាដេសបានៀរ គឺជាទីកន្លែងដែលកាលកូនចៅអ៊ីស្រាអែលត្រឡប់ពីអេស៊ីព្ទវិញ អ្នកស្រុកម្ដុំនេះ មិនអនុញ្ញាតអោយគេឆ្លងកាត់ដីនោះឡើយ។ លោកអ័ប្រាហាំ ធ្វើដំណើរទៅដល់ស្រុកត្បូង ក៏តាំងទីលំនៅនៅតំបន់កេរ៉ា។ តាមយោបល់ខ្ញុំ លោកមិនគួរធ្វើដំណើរទៅតាំងទីលំនៅនៅទីនោះទេ ប៉ុន្តែក្នុងសាច់រឿងនេះ បាននិយាយថា នៅទីនោះ លោកនិយាយពាក្យភូតភរពីដំណើរនាងសារ៉ា។

ខ្ញុំសុំផ្តោតការយកចិត្តទុកដាក់ខ្លាំង ទៅលើការលន់តួបាបរបស់លោកអ័ប្រាហាំ ពីព្រោះសេចក្តីនេះជាសាច់រឿងស្នូល របស់ជំពូក២០នេះតែម្តង។ លោកអ័ប្រាហាំ

និងសារ៉ាមិនអាចទទួលអ៊ីសាកមកធ្វើជាកូនរបស់ខ្លួនផ្ទាល់បានទេ បើប្រសិនណាជាអ្នកទាំងពីរ មិនព្រមជំរះអំពើបាប ដែលមាននៅក្នុងជីវិតរបស់លោកឡើយ។

> **អ័ប្រាហាំទូលថា ពីព្រោះទូលបង្គំនឹកថា ប្រាកដជាគ្មានសេចក្ដីកោតខ្លាចដល់ព្រះនៅទីនេះទេ ហើយថា គេនឹងសំឡាប់ទូលបង្គំចោលដោយព្រោះប្រពន្ធទូលបង្គំនេះ (លោកុ.២០:១២)។**

លុះមានគេជាន់កែងលោកជាប់ អ័ប្រាហាំទូលស្ដេចអ័ប៊ីម៉្មាឡិចថា "ខ្ញុំបានភរទ្រង់តែពាក់កណ្ដាលទេ ពីព្រោះតាមពិតទៅ នាងសារ៉ានេះ ជាប្អូនទូលបង្គំមែន ប៉ុន្តែមិនមែនម្ដាយជាមួយគ្នាទេ ហើយខ្ញុំក៏យកនាងជាប្រពន្ធរបស់ខ្ញុំទៅ"។

> **កាលព្រះទ្រង់ បានធ្វើឱ្យទូលបង្គំដើរចាកចោលផ្ទះឪពុកមកនោះ ទូលបង្គំបាននិយាយនឹងនាងថា ត្រូវឱ្យឯងអាណិតដល់អញយ៉ាងនេះ គឺនៅកន្លែងណាដែលយើងទៅ នោះត្រូវនិយាយពីអញថាជាបងឯង (លោកុ.២០:១៣)។**

សេចក្ដីត្រង់នេះបញ្ជាក់ថា លោកអ័ប្រាហាំ មិនបានទុកចិត្តពេញទីដល់ព្រះជាម្ចាស់ទេ។ មុនពេលចេញដំណើរពីស្រុកកំណើត លោកហើយនិងនាងសារ៉ាបាន

ធ្វើកិច្ចសន្យាជាមួយគ្នាថា នៅទីណាដែលលោកអ័ប្រាហាំអាចទទួលគ្រោះថ្នាក់ដល់ស្លាប់ ទាក់ទងនឹងប្រពន្ធរបស់លោក នៅទីនោះសារ៉ាត្រូវហៅលោកអ័ប្រាហាំថាជាបងវិញ។ ដំណោះស្រាយនេះ អ្នកទាំងពីរជឿថា អាចជួយដល់ជីវិតអ័ប្រាហាំ មិនអោយស្លាប់បាន។ អ្នកទាំងពីរប្រហែលជា មិនយល់ស្របជាមួយគ្នា១០០%ទេ ប៉ុន្តែទោះបីយ៉ាងនោះក៏ដោយ អ្នកទាំងពីរបានប្រព្រឹត្តអំពើបាបនោះ។ ដំបូងអ្នកទាំងពីរភូតភររឿងនោះនៅស្រុកអេស៊ីព្ទ ឥឡូវនេះ គេប្រព្រឹត្តបាបដដែលនោះម្តងទៀតហើយ។ អ្នកទាំងពីរត្រូវតែជំរះបាបភូតភរនេះ ទើបព្រះអង្គព្រមឆ្លើយតប នឹងសេចក្តីអធិស្ឋានរបស់អ័ប្រាហាំ ថាទ្រង់នឹងប្រទានអោយមានកូនប្រុសមួយ។ លោកមិនអាចទទួលយកអ៊ីសាកជាកូនប្រុសមួយបានទេ ទាល់តែលោកព្រមជំរះអំពើបាបបែបនេះ ចេញពីជីវិតរបស់លោកជាមុនសិន។

លោកអ្នកបងប្អូនអើយ សព្វថ្ងៃនេះ មានគ្រីស្ទបរិស័ទច្រើនណាស់ ដែលមិនព្រមជំរះអំពើបាប ដែលខ្លួនមានចេញពីក្នុងជីវិតរបស់ខ្លួនទេ។ ដូច្នេះហើយ បានជាគ្មានព្រះពរណាល្អកើតឡើង នៅក្នុងជីវិតរបស់គេសោះ។ បើប្រសិនណាជាពួកអ្នកដឹកនាំនៅក្នុងក្រុមជំនុំរបស់ព្រះអង្គសព្វថ្ងៃនេះ ព្រមជំរះអំពើបាបចេញពីក្នុងចិត្ត ក្នុងគំនិតរបស់គេ ខ្ញុំជឿពិតប្រាកដថា ក្រុមជំនុំរបស់ព្រះអង្គសព្វថ្ងៃនេះ នឹងមានការកក្រើករំពើកជាមិនខានឡើយ។ ខ្ញុំផ្ទាល់មិនជឿថា មានព្រះពរណាកើតឡើងដល់ក្រុមជំនុំទេ លើកលែងតែពួកអ្នកដឹកនាំក្រុមជំនុំ និងពួកអ្នកជឿសុខចិត្តលះចោល ទាំងជំរះអំពើបាបដែលខ្លួនកំពុងតែប្រព្រឹត្តផង។ សូមលោកអ្នកបងប្អូន ស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ដែលទ្រង់មានបន្ទូលតាមរយៈសាវ័កប៉ូល ដែលចែងយ៉ាងដូច្នេះថា "ត្រូវអោយមនុស្ស

ល្បងខ្លួនឯងមើល រួចសឹមបរិភោគនំប៉័ង ហើយផឹកពីនេះពែងចុះ ដ្បិតអ្នកណាដែល បរិភោគបែបមិនគួរសម អ្នកនោះឈ្មោះថាបរិភោគជាសេចក្ដីជំនុំជំរះ ដល់ខ្លួនវិញ ដោយព្រោះមិនពិចារណា ឃើញរូបអង្គនៃព្រះអម្ចាស់ទេ គឺដោយហេតុនោះ បានជា មានអ្នករាល់គ្នាជាច្រើន ទៅជាខ្សោយ ហើយឈឺក៏មានគ្នាជាច្រើនដេក លក់ទៅ ហើយដែរ។ បើសិនជាយើងរាល់គ្នាពិចារណា មើលក្នុងខ្លួនយើងនោះ យើងមិនត្រូវ ជាប់ជំនុំជំរះទេ តែកាលណាយើងរាល់គ្នាត្រូវជាប់ជំនុំជំរះនោះ ព្រះអម្ចាស់ទ្រង់វាយ ផ្ចាលយើងវិញ ដើម្បីកុំអោយយើងជាប់ទោស ជាមួយនឹងលោកីយ៍ឡើយ" (១កូរិថូស ១១:២៨-៣២)។ សព្វថ្ងៃនេះ ព្រះពរត្រូវមានការរាំងស្ទះដល់ក្រុមជំនុំ ក៏ដូចជាដល់ ជីវិតរបស់អ្នកជឿនៅតាមក្រុមជំនុំនានាដែរ បើប្រសិនណាជាក្រុមជំនុំនិងអ្នកជឿមិន ព្រមជំរះអំពើបាបដែលមាននៅក្នុងចិត្តខ្លួននោះទេ។ នៅក្នុងព្រះគម្ពីរលោកុប្បត្តិជំពូក ២០នេះ យើងមានមេរៀនខាងព្រលឹងវិញ្ញាណយ៉ាងឧដុង្គឧត្ដម ស្ដីអំពីការជំរះអំពើ បាប ដើម្បីអោយបានទទួលព្រះពរបន្ថែមមកទៀត នៅក្នុងជីវិតបុគ្គលម្នាក់ៗ ក៏ដូចជា ដល់ក្រុមជំនុំផងដែរ។